# សេចក្តីប្រកាសព័ត៌មាន

**វឌ្ឍនភាពចំពោះការដោះមីនត្រូវបានកត់សំគាល់នៅក្នុងកិច្ចប្រជុំពិភពលោកនៅកម្ពុជាៈ ប្រទេសប៊ូរុនឌី និងនីហ្សេរីយ៉ាប្រកាសថាប្រទេសរបស់ខ្លួនគ្មានគ្រាប់មីនឡើយ**

*ភ្នំពេញ កម្ពុជា ថ្ងៃ ទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១-* ប្រទេសប៊ូរុនឌី និងនីហ្សេរីយ៉ាបានក្លាយជាប្រទេសចុងក្រោយបំផុត ដែលប្រកាសថាប្រទេសរបស់ពួកគេគ្មានគ្រាប់មីនប្រឆាំងមនុស្សទៀតឡើយ។ សេចក្តីប្រកាសនេះត្រូវបានថ្លែងនៅពីរថ្ងៃដំបូងនៃកិច្ចប្រជុំលើកទីដប់មួយនៃរដ្ឋភាគី (11MSP) នៃអនុសញ្ញាស្តីពីការហាមប្រាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន ឬ *អនុសញ្ញាអូតាវ៉ា* ។

"ខ្ញុំសូមអបអរសាទរចំពោះប្រទេសប៊ូរុនឌី និងនីហ្សេរីយ៉ាចំពោះការប្រកាសថាប្រទេសទាំងពីរនេះបានបោសសំអាតនូវតំបន់នានាដែលមានគ្រាប់មីន ស្របតាមកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញាស្តីពីការហាមប្រាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន"នេះជាប្រសាសន៍របស់ ឯ.ឧ. ប្រាក់ សុខុន រដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រី និងជាប្រធានកិច្ចប្រជុំ 11MSP ។

"ខណៈពេលដែលនៅសេសសល់ការងារដ៏ច្រើនក្នុងការបោសសំអាតគ្រាប់មីននៅកម្ពុជា យើងត្រូវបានលើកទឹកចិត្តដោយកិច្ចប្រឹងប្រែងរបស់ប៊ូរុនឌី និងនីហ្សេរីយ៉ា" នេះជាប្រសាសន៍របស់ ឯ.ឧ. ប្រាក់ សុខុន។ "កិច្ចប្រឹងប្រែងរបស់ប្រទេសទាំងពីរពុំមែនគ្មានផ្លែផ្កានោះទេ។ ប្រទេសប៊ូរុនឌី និងនីហ្សេរីយ៉ាបានផ្តល់នូវពន្លឺនៃក្តីសង្ឃឹម" ។

សេចក្តីប្រកាសរបស់ប៊ូរុនឌីអំពីការបញ្ចប់ការបោសសំអាតមីន ថ្លែងដោយរដ្ឋមន្ត្រីសន្តិសុខសាធារណៈ។ ការងាររបស់ប៊ូរុនឌីធានាថាតំបន់ចំនួន ២៤៦ ដែលសង្ស័យថាមានគ្រោះថ្នាក់ មានផ្ទៃដីសរុបចំនួន ២៩ គីឡូម៉ែត្រការ៉េ ឥឡូវត្រូវបានបោសសំអាតគ្រាប់មីនប្រឆាំងមនុស្ស និងសំណល់ជាតិផ្ទុះពីសង្គ្រាម។

កិច្ចប្រឹងប្រែងរបស់ប្រទេសនីហ្សេរីយ៉ា អនុលោមតាមកាតព្វកិច្ចបោសសំអាតគ្រាប់មីនរបស់អនុញ្ញាអូតាវ៉ា រួមមាន ការបោសសំអាតផ្ទៃដី ៧៥.១៧៨ គីឡូម៉ែត្រការ៉េដែលសង្ស័យថាមានគ្រាប់មីនប្រឆាំងមនុស្ស ឬសំណល់

**AP Mine Ban Convention Implementation Support Unit**

GICHD | 7bis, avenue de la Paix | P.O. Box 1300 | 1211 Geneva 1 | Switzerland | t. + 41 (0) 79 960 2274
f. + 41 (0)22 906 16 90 | isu@apminebanconvention.org | **www.apminebanconvention.org** | **www.11msp.org**

ជាតិផ្ទុះពីសង្គ្រាមដទៃទៀត។ គ្រាប់មីនធម្មតាចំនួន ៨២០ គ្រាប់ និងមីនច្នៃចំនួន ៦៤៦ គ្រាប់ ឬជាប្រភេទមីន "ogbunigwe" ត្រូវបានបំផ្លាញ ទន្ទឹមនឹងការបំផ្លាញបរិធានផ្ទុះដទៃទៀតជាច្រើន។

ក្នុងការបង្ហាញសេចក្តីថ្លែងការណ៍អំពីការបញ្ចប់ការបោសសំអាតគ្រាប់មីនទៅកាន់កិច្ចប្រជុំ 11MSP គណៈប្រតិភូរបស់ប្រទេសនីហ្សេរីយ៉ាបានថ្លែងថា "នីហ្សេរីយ៉ាដឹងថាបញ្ហាប្រឈមនៃមាត្រា ៥ ពុំមានលក្ខណៈធ្ងន់ធ្ងរដូចប្រទេសរងគ្រោះដទៃទៀតជួបប្រទះនោះទេ។ ទោះជាយ៉ាងណាក្តី ការគោរពតាមស្មារតីនៃអនុសញ្ញាអូតាវ៉ានៅតែតម្រូវឱ្យមានការប្រឹងប្រែងដោយយកចិត្តទុកដាក់"។

ជាមួយនឹងសេចក្តីថ្លែងការណ៍របស់ប្រទេសប៊ូរុនឌី និងនីហ្សេរីយ៉ា សព្វថ្ងៃមានរដ្ឋភាគីចំនួន ១៩ ដែលបានរាយការណ៍ថាបានបញ្ចប់កាតព្វកិច្ចដោះមីនរបស់ខ្លួន ក្នុងចំណោមប្រទេសសរុបចំនួន ៥៤ ដែលបានរាយការណ៍អំពីការទទួលខុសត្រូវក្នុងការបោសសំអាតតំបន់មានមីនទាំងអស់ ដែលស្ថិតក្រោមយុត្តាធិការ ឬស្ថិតក្រោមការគ្រប់គ្រងរបស់ពួកគេ។

## អនុសញ្ញាស្តីពីការហាមប្រាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន

អនុសញ្ញាស្តីពីការហាមប្រាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីនត្រូវបានអនុម័តនៅទីក្រុង អូស្លូ នៅឆ្នាំ ១៩៩៧ ដែលបើកឱ្យចុះហត្ថលេខានៅទីក្រុងអូតាវ៉ាក្នុងឆ្នាំដដែល ហើយចូលជាធរមាននៅឆ្នាំ ១៩៩៩។

រហូតដល់ដល់ពេលនេះ មានរដ្ឋចំនួន ១៥៨ បានចូលជារដ្ឋភាគីនៃអនុសញ្ញានេះ ក្នុងនោះ រដ្ឋភាគី ១៥៣ រាយការណ៍ថាពួកគេលែងរក្សាទុកគ្រាប់មីនប្រឆាំងមនុស្សទៀតហើយ។ មីននៅក្នុងឃ្លាំងចំនួន ៤៤.៥ លានគ្រាប់ត្រូវបានបំផ្លាញដោយរដ្ឋភាគីទាំងនោះ។

រដ្ឋ ៣៤ ក្នុងចំណោម ៥០ ដែលកាលពីមុនបានផលិតគ្រាប់មីនប្រឆាំងមនុស្ស សព្វថ្ងៃជាប់កាតព្វកិច្ចគោរពអនុញ្ញាស្តីពីការហាមប្រាមការផលិតគ្រាប់មីន។ ភាគីភាគច្រើនដទៃទៀតបានដាក់ឱសានវាទចំពោះការផលិត និង/ឬការផ្ទេរគ្រាប់មីន។

ជាលទ្ធផលការដោះមីនធ្វើឱ្យផ្ទៃដីរាប់លានម៉ែត្រការ៉េ ដែលពីមុនធ្លាប់ជាដីមានគ្រោះថ្នាក់ ត្រូវបានរំដោះសម្រាប់សកម្មភាពរបស់មនុស្សជាតិ។

###

ចំពោះកិច្ចសម្ភាសន៍ ឬព័ត៌មានបន្ថែមអំពីទិដ្ឋភាពណាមួយនៃអនុញ្ញានេះ សូមផ្ញើអ៊ីម៉ែលទៅកាន់: ISU@APMineBanConvention.org ឬទាក់ទងអ្នកស្រី Laila Rodriguez តាមទូរស័ព្ទលេខ +855 97 6890 977 ឬ +41 79 960 2274។ ភ្ជាប់ទៅអនុញ្ញានេះ តាមរយៈ website, Facebook, Flickr ឬ Twitterរបស់យើង។